ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.៥១៦.....សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែសីហា ឆ្នាំ២០១៥

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការប្រើប្រាស់ថវិកា សម្រាប់ប្រាក់រង្វាន់លើកទឹកចិត្ត និងពង្រឹងយន្តការ នៃការកៀរគរ និងប្រមូលចំណូលសួយសារធនធានរ៉ែ

## រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## រដ្ឋមន្ត្រី ក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម លេខ នស / រកម / ១២១៣ / ០១៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៧៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងរ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសលេខ ៩២៧ ឧរថ អធរ.ប្រក ចុះថ្ងៃទី០៧ ខែធ្នូ ២០០៥ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតគណៈកម្មាធិការអន្តរក្រសួង ដើម្បីកំណត់ និងវាយតម្លៃការបង់ថ្លៃវត្ថុធាតុដើមថ្មសម្ភារសំណង់ ធនធានរ៉ែលោហៈ-អលោហៈ រ៉ែត្បូងថ្មមានតម្លៃ-ពាក់កណ្តាលមានតម្លៃ ថ្មសំអាង និងធនធានរ៉ែឥន្ធនៈរឹង
- បានឃើញប្រកាសលេខ ៣៦២ សហវ ប្រក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការបង្កើតក្រុមការងារទារបំណុល ថ្លៃឈ្នួលរោងចក្រ សហគ្រាស និងអចលនវត្ថុរដ្ឋ ព្រមទាំងចំណូលមិនមែនសារពើពន្ធរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៤ លើលិខិតលេខ ៣២២៦ សហវ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់នៃការងារ

## សម្រេច

**ប្រការ ១.-**

ត្រូវបានអនុញ្ញាតឲ្យក្រសួងរ៉ែ និងថាមពល កាត់ទុកជាមុនចំនួន ១០ % (ដប់ភាគរយ) នៃប្រាក់ចំណូលសួយសារធនធានរ៉ែ (ហៅកាត់ថា "ប្រាក់កាត់ទុក") ដើម្បីប្រើប្រាស់ជាប្រាក់រង្វាន់លើកទឹកចិត្ត និងពង្រឹងយន្តការនៃការកៀរគរ និងប្រមូលចំណូលសួយសារធនធានរ៉ែ ។ ការកាត់ទុកមុននូវ ប្រាក់រង្វាន់នេះ ត្រូវអនុវត្តចាប់ពីថ្ងៃប្រកាសអន្តរក្រសួងនេះ ចូលជាធរមាន ។ ចំណែក ៩០% (កៅសិបភាគរយ) នៃប្រាក់ចំណូលសួយសារធនធានរ៉ែដែលនៅសល់ ត្រូវបង់ចូលថវិការដ្ឋ ។

**ប្រការ ២.-**

ក្រសួងរ៉ែ និងថាមពល ត្រូវធ្វើសំណើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបុរេប្រទានប្រាក់រង្វាន់ចំនួន ១០ % នៃចំណូលសួយសារធនធានរ៉ែ ដែលក្រុមហ៊ុន-អាជីវករ បានបង់ចូលថវិការដ្ឋ ចន្លោះពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៤ រហូតដល់ប្រកាសអន្តរក្រសួងនេះ ចូលជាធរមាន ហើយបែងចែក និងប្រើប្រាស់ប្រាក់រង្វាន់នេះ តាមការកំណត់ក្នុងប្រការ ៤ នៃប្រកាសអន្តរក្រសួងនេះ ។

**ប្រការ ៣.-**

ក្រសួងរ៉ែ និងថាមពល ត្រូវបង្កើតគណនីចរន្តនៅធនាគារជាតិនៃកម្ពុជា ដើម្បីទទួលប្រាក់រង្វាន់ចំនួន ១០ % នៃចំណូលសួយសារធនធានរ៉ែ។ ក្រសួងរ៉ែ និងថាមពល ប្រើប្រាស់គណនីនេះ ក្នុងការចំណាយបែងចែកជូនតាមបណ្តាអង្គភាពគោលដៅ តាមការកំណត់ក្នុងប្រការ ៤ នៃប្រកាសអន្តរក្រសួងនេះ ព្រមទាំងសម្រាប់លើកផ្តល់លើកទឹកចិត្តដល់មន្ត្រីរាជការនៃក្រសួងរ៉ែ និងថាមពល ។

**ប្រការ ៤.-**

ប្រាក់កាត់ទុក ត្រូវបាត់ចែងបែងចែកដូចខាងក្រោម៖

ក- ចំនួន ៣០% នៃប្រាក់កាត់ទុក ផ្តល់ជូនក្រសួងរ៉ែ និងថាមពល សម្រាប់ប្រើប្រាស់ជារង្វាន់លើកទឹកចិត្តជូនមន្ត្រីក្រសួងរ៉ែ និងថាមពល ។

ខ- ចំនួន ២០% នៃប្រាក់កាត់ទុក ផ្តល់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ប្រើប្រាស់ជារង្វាន់លើកទឹកចិត្តជូនមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងគណៈកម្មាធិការអន្តរក្រសួង និងក្នុងក្រុមការងារទារបំណុលថ្លៃឈ្នួលរោងចក្រ សហគ្រាស និងអចលនវត្ថុរដ្ឋ ព្រមទាំងចំណូលមិនមែនសារពើពន្ធរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលត្រូវបានបង្កើតឡើងដោយប្រកាសលេខ ៣៦២ សហវ.ប្រក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ហៅកាត់ថា "ក្រុមការងារទារបំណុលអន្តរក្រសួង") ។

គ- ចំនួន ១០% នៃប្រាក់កាត់ទុក ត្រូវផ្តល់ជូនសាលារាជធានី ខេត្ត និងអង្គភាពថ្នាក់ក្រោមជាតិពាក់ព័ន្ធ សម្រាប់ប្រើប្រាស់ជារង្វាន់លើកទឹកចិត្តជូនមន្ត្រី ដែលបានចូលរួមផ្ទាល់ក្នុងការងារកៀរគរ និងប្រមូលចំណូលសួយសារធនធានរ៉ែ ។

ឃ- ចំនួន ៦% នៃប្រាក់កាត់ទុក ត្រូវផ្តល់ជូនមន្ទីររ៉ែ និងថាមពល រាជធានី ខេត្តពាក់ព័ន្ធ សម្រាប់ប្រើប្រាស់ជារង្វាន់លើកទឹកចិត្តជូនមន្ត្រី ដែលបានចូលរួមផ្ទាល់ក្នុងការងារកៀរគរ និងប្រមូលចំណូលសួយសារធនធានរ៉ែ។

ង- ចំនួន ៤% នៃប្រាក់កាត់ទុក ត្រូវផ្តល់ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជធានី ខេត្តពាក់ព័ន្ធ សម្រាប់ប្រើប្រាស់ជារង្វាន់លើកទឹកចិត្តជូនមន្ត្រី ដែលបានចូលរួមផ្ទាល់ក្នុងការងារកៀរគរ និងប្រមូលចំណូលសួយសារធនធានរ៉ែ ។

ច- ចំនួន ៣០% នៃប្រាក់កាត់ទុក ត្រូវប្រើប្រាស់សម្រាប់ចំណាយកិច្ចការចាំបាច់នានា ក្នុងគណៈកម្មាធិការអន្តរក្រសួង ដើម្បីពង្រឹងយន្តការនៃការកៀរគរ និងប្រមូលចំណូលសួយសារធនធានរ៉ែឲ្យមានប្រសិទ្ធភាព ។

**ប្រការ ៥.-**

ការគ្រប់គ្រង បែងចែក និងប្រើប្រាស់ប្រាក់កាត់ទុកដូចមានចែងក្នុងចំណុច ក ចំណុច ឃ និងចំណុច ច នៃប្រការ ៤ ខាងលើ ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល ។

ការគ្រប់គ្រង និងបែងចែកប្រាក់កាត់ទុកក្នុងចំណុច ខ និងចំណុច ង នៃប្រការ ៤ ខាងលើ ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ប្រធានក្រុមការងារទារបំណុលអន្តរក្រសួង ។

ការគ្រប់គ្រង និងបែងចែកប្រាក់កាត់ទុកក្នុងចំណុច គ នៃប្រការ ៤ ខាងលើត្រូវសម្រេចដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្តពាក់ព័ន្ធ ។

**ប្រការ ៦.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៧.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងរ៉ែ និងថាមពល អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ ឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងរ៉ែ និងថាមពល**

**ស៊ុយ-សែម**

**ចម្លងជូន**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-អាជ្ញាធរសវនកម្មជាតិ
-អង្គភាពប្រឆាំងអំពើពុករលួយ
"ដើម្បីជូនជ្រាប"
-ដូចប្រការ៧ "ដើម្បីមុខការ"
-ឯកសារ-កាលប្បវត្តិ